សាលាព្រះគម្ពីរភ្នំពេញ

លេខ១: ខែមីនា ២០១៥

# ខាលស្រែស្រូវទុំ

ប្រសាសន៍របស់លោកមហាវិទ្យាធិការ ទេព សំណាង

www.ppbs.edu.kh

## និមិត្តរបស់សាលាព្រះគម្ពីរភ្នំពេញ

"រៀបចំអ្នកបម្រើព្រះនៅក្នុងប្រទេសកម្ពុជា ដើម្បីឲ្យគេបំពេញមហាបេសកកម្មថ្វាយព្រះជាម្ចាស់" គឺជានិមិត្តរបស់សាលាព្រះគម្ពីរភ្នំពេញ(PPBS)។ លោកដានីយ៉ែល យីវ៉ា ឡាំ(Daniel Yee-Wah Lam) គឺជាពាណិជ្ជករជនជាតិចិន-អាមេរិក ដែលព្រះបានដឹកនាំមកកម្ពុជា នៅដើមឆ្នាំ១៩៩០ ព្រះបានប្រទានឲ្យគាត់មានចិត្តចង់ឃើញបងប្អូនគ្រីស្ទានកម្ពុជាប្រកាសដំណឹងល្អគ្រប់ទីកន្លែងទូទាំងប្រទេសកម្ពុជា។ តាមរយៈនិមិត្តនេះ ក្នុងឆ្នាំ១៩៩២ លោកបានបង្កើតសាលាព្រះគម្ពីរភ្នំពេញនេះឡើង។ ជារៀងរាល់ថ្ងៃបន្ទាប់ពីរៀននៅក្នុងថ្នាក់រួច លោកចាត់បញ្ជូននិស្សិតឲ្យចេញទៅផ្សាយដំណឹងល្អ។ ទោះបីជាមានការបៀតបៀនជាខ្លាំងនៅពេលនោះ តែពួកនិស្សិតបានប្រកាសដំណឹងល្អដោយក្តីអំណរ ដោយគ្មានភ័យខ្លាច ហើយពួកគេបានមើលឃើញមនុស្សជាច្រើនចាប់ផ្តើមស្គាល់ព្រះ។ ជាលទ្ធផល ឃើញថា មានពួកជំនុំជាច្រើនបានបង្កើតឡើង ហើយដីនិងអាគារត្រូវបានបរិច្ចាកដោយឥតគិតថ្លៃ។

ទោះបីលោកដានីយ៉ែល'បានវិលទៅផ្ទះ' ទៅនៅជាមួយព្រះអម្ចាស់របស់លោកវិញក៏ពិតមែន តែនិមិត្តរបស់លោកនៅតែជាគ្រឹះនៃPPBS។ ខណៈដែលសង្គមកម្ពុជាកំពុងអភិវឌ្ឍទៅមុខ នោះយើងបន្តការអភិវឌ្ឍផែនការជាយុទ្ធសាស្ត្រ និងកម្មវិធីរបស់សាលាដើម្បីសម្រេចនិមិត្តនេះ។ សញ្ញាបត្របរិញ្ញាបត្រព័ន្ធកិច្ចគ្រីស្ទាននៅបន្តជាកម្រិតកម្មវិធីសិក្សារបស់សាលា ហើយយើងបានផ្តល់នូវវគ្គសិក្សាបរិញ្ញាបត្រផ្នែកទេវសាស្ត្រដល់និស្សិតនៅឆ្នាំទីបីរបស់ពួកគេ។ យើងមានថ្នាក់រៀនមុខវិជ្ជា"ផ្សាយដំណឹងល្អ" និង"បេសកកម្ម និងវប្បធម៌" ដែលទាក់ទងផ្ទាល់ទៅនឹងបេសកកម្ម។ យើងមានគោលបំណងចង់ឲ្យនិស្សិតរបស់យើងរៀន និងដាស់តឿនចិត្តពួកគេឲ្យគាំទ្រដល់មហាបេសកកម្ម។ នៅក្នុងកម្មវិធីសិក្សាទាំងមូលសាស្ត្រាចារ្យទាំងអស់តែងរំឭក និងលើកទឹកចិត្តនិស្សិតតាមវិធិសាស្ត្រផ្សេងៗឲ្យគាំទ្រដល់មហាបេសកកម្ម។

និស្សិតមិនត្រឹមតែទទួលចំណេះដឹងនៅក្នុងខួរក្បាលប៉ុណ្ណោះ ប៉ុន្តែពួកគេបន្ត'អនុវត្តនូវទេវសាស្ត្រ'ដែលពួកគេបានរៀន។ ពួកគេម្នាក់ៗតែងតែវិលត្រឡប់ទៅបម្រើព័ន្ធកិច្ចពួកជំនុំដើម/ពួកជំនុំដែលបានទំនុកបម្រុងពួកគេរៀន ។ មួយឆ្នាំម្តង សាលារៀបចំកម្មវិធីចុះធ្វើព័ន្ធកិច្ចកម្មសិក្សាតាមពួកជំនុំជាបណ្តាញរបស់សាលា។ យើងធ្វើដំណើរទៅខេត្តជាច្រើន ដើម្បីផ្សព្វផ្សាយពីនគរព្រះ។ យើងមានអារម្មណ៍រំភើបជានិច្ចក្នុងការធ្វើការនេះ ខណៈដែលយើងមើលឃើញពួកជំនុំរីកចម្រើន និងពង្រីកទៅកន្លែងផ្សេងៗ។ យើងកំពុងរៀបផែនការផ្តល់កម្មវិធីធ្វើដំណើរចុះធ្វើបេសកម្មជាច្រើនទៀត និងបន្ថែមការផ្តោតអារម្មណ៍លើការអធិស្ឋានសម្រាប់បេសកកម្មផងដែរ។

ការប្រកាន់ខ្ជាប់នូវនិមិត្តនេះផ្តល់ផលវិជ្ជមានដល់ថ្នាក់ដឹកនាំនៃPPBS។ គណកម្មការនាយកគ្រប់គ្រងសាលាមានផែនការជាយុទ្ធសាស្ត្រតែងតាំងជនជាតិខ្មែរជាសមាជិកសាស្ត្រាចារ្យនិងអ្នកដឹកនាំសាលា គឺថាគ្រីស្ទានក្នុងស្រុកបានរៀបចំចិត្តដើម្បីស្លាប់រស់នៅក្នុងទឹកដីរបស់ពួកគាត់- ពួកគាត់បានត្រឡប់ជាមនុស្សដ៏សំខាន់ ដើម្បីបណ្តុះបណ្តាលដល់សាសន៍របស់ខ្លួន។ គណកម្មការនាយកផ្ទាល់មានគម្រោងចង់ឲ្យមានសមាជិកគណកម្មការនាយកភាគច្រើនជាជនជាតិខ្មែរនៅថ្ងៃអនាគត។

ហេតុនេះ យើងសូមអញ្ជើញលោកអ្នកចូលរួមជាមួយយើងក្នុងការរៀបចំអ្នកបម្រើព្រះក្នុងប្រទេសកម្ពុជាឲ្យបំពេញមហាបេសកកម្ម។ ពេលលោកអ្នកមានឱកាស សូមអញ្ជើញមកធ្វើទស្សនកិច្ចនៅសាលាយើង។ យើងជឿជាក់ថា លោកអ្នកនឹងទទួលការបណ្តាលចិត្តឲ្យគិតពិចារណាយកPPBSជាកន្លែងសម្រាប់បណ្តុះបណ្តាលខ្លួនអ្នកផ្ទាល់និងបងប្អូនគ្រីស្ទានដែលអ្នក ចង់ហ្វឹកហ្វឺនឲ្យបំពេញមហាបេសកកម្មថ្វាយសិរីល្អដល់ព្រះនៅ ក្នុងប្រទេសកម្ពុជា។














ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិ
បុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនា
វិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀន
បានបង្គាប់មកអ្នករាល់គ្នាផង ហើយ
រាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។ អា

**ព័ន្ធកិច្ចកម្មសិក្សាឆ្នាំ២០១៥** បានជះឥ
យើងបានគិតថាពេលយើងចេញទៅ
ស្វាគមន៍យើងនិងចាប់អារម្មណ៍យ៉ាង
ជនបទជាច្រើនយ៉ាងខ្លាំង របៀបធ្វើ
របៀបមួយដ៏ត្រឹមត្រូវ។ និស្សិតជាច្រើ
សាស្ត្រាចារ្យ និងគ្រូគង្វាលបានប្រព្រឹ
ជាមួយមនុស្សពីក្រុមផ្សេងៗដូចជាជា
ខេ មន្ត្រីប៉ូលីស និងក្មេងៗយ៉ាងច្រើន
កន្លែងក្នុងប្រទេសកម្ពុជា ហើយបន្តនាំ

# ប់កម្ពុជា










ស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើ
មព្រះវរបិតា ព្រះរាជបុត្រា និងព្រះ
ឲ្យគេកាន់តាមគ្រប់ទាំងសេចក្តីដែលខ្ញុំ
មើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នា ជា
ម៉ែន។ (ម៉ាថាយ ២៨:១៩-២០)

ទ្ធិពលដល់និស្សិតPPBSតាមរបៀបផ្សេងៗជាច្រើន។ ក្រុមតូចឈ្មោះក្រុមចង្កៀងបានចែករំលែកថា: "នៅពេលដំបូងពួក
ព្រាយដំណឹងល្អឬចែករំលែកនៅក្នុងព្រះវិហារ ប្រហែលជាអ្នកចូលរួមនឹងមិនចាប់អារម្មណ៍ទេ តែផ្ទុយទៅវិញពួកគេបាន
ខ្លាំងចំពោះដំណឹងល្អ" ។ មេរៀនជាច្រើនទៀតដែលយើងបានរៀនគឺមានសេចក្តីត្រូវការការផ្សាយដំណឹងល្អនៅតាមតំបន់
ន្ធកិច្ចជាមួយក្មេងៗ របៀបប្រឈមនឹងសេចក្តីភ័យខ្លាចនៅពេលធ្វើអ្វីដែលថ្មី និងការសុំអនុញ្ញាតពីមន្រ្តីរដ្ឋាភិបាលក្នុង
នបានអរព្រះគុណដល់ព្រះចំពោះការបន្ទាបខ្លួន សេចក្តីស្រឡាញ់ និងឥរិយាបថជាអ្នកបម្រើដែលមិត្តនិស្សិត ក្រុម
ក្តដល់ពួកគេក្នុងពេលពួកគេស្នាក់នៅនិងបម្រើព័ន្ធកិច្ចជាមួយគ្នាក្នុងស្ថានភាពលំបាកនានា។ សមត្ថភាពអាចធ្វើការ
មួយបងប្អូនវៀតណាម ខ្មែរអ៊ីស្លាម ក៏ដូចជានៅកន្លែងខុសៗគ្នា ដូចជានៅតាមព្រំដែន ផ្សាយដល់អ្នកធ្វើការក្នុងខារ៉ាអូ
ទាំងនេះបានផ្តល់ទស្សនគំនិតយ៉ាងវិជ្ជមានអំពីការផ្សាយដំណឹងល្អនិងដាំពួកជំនុំដែលទំនុកបម្រុងខ្លួនឯងនៅគ្រប់ទី
ការផ្លាស់ប្តូរដល់ជីវិតពួកគេផ្ទាល់និងគ្រប់ទីកន្លែងដែលពួកគេធ្វើព័ន្ធកិច្ចបម្រើព្រះនៅថ្ងៃអនាគត។

## តើបច្ចុប្បន្ននេះពួកគាត់នៅឯណា?



ព្រំ សុធា និងភរិយាបានសិក្សានៅសាលាព្រះគម្ពីរភ្នំពេញ។ សុធាបានទទួលសញ្ញាបត្របរិញ្ញាបត្រផ្នែកព័ន្ធកិច្ចគ្រីស្ទាន ហើយ គន្ធា ភរិយារបស់គាត់ទទួលសញ្ញាបត្រថ្នាក់មូលដ្ឋានគ្រឹះព័ន្ធកិច្ចគ្រីស្ទាន។ ពួកគាត់ត្រូវបានចាត់បញ្ជូនធ្វើជាបេសកជនទៅផ្សាយដំណឹងល្អដល់កុលសម្ព័ន្ធក្នុងនៅខេត្តមណ្ឌលគីរី។ ពួកគាត់កំពុងរួមចំណែកក្នុងការបណ្ដុះបណ្ដាលនិងផ្ដល់ប្រឹក្សាដល់គ្រូគង្វាលជាជនជាតិភ្នងជាច្រើនដែលដឹកនាំពួកជំនុំចំនួន១០ មានសមាជិកពួកជំនុំជិត២០០នាក់។ ពួកគាត់ក៏មានចំណែកក្នុងការប្រកាសដំណឹងល្អ ជួយដាំពួកជំនុំថ្មីៗ និងកំពុងឈោងចាប់ដល់កុលសម្ព័ន្ធជាច្រើនទៀតនៅខេត្តមណ្ឌលគីរី។

សុធានិងគន្ធាបានរៀបការជាង១០ឆ្នាំមកហើយ ហើយបានហែលឆ្លងនូវការលំបាកយ៉ាងច្រើន តែពួកគាត់បានតស៊ូបម្រើព័ន្ធកិច្ចដែលព្រះជាម្ចាស់បានដឹកនាំ។ ក្រៅពីការលំបាកផ្នែករៀនភាសាថ្មី និងការរស់ក្នុងព័ន្ធកិច្ច ពួកគាត់បានអធិស្ឋានអស់ជាច្រើនឆ្នាំ សូមព្រះជាម្ចាស់ប្រទាន បុត្រ១ដល់ពួកគាត់ នៅទីបំផុតព្រះជាម្ចាស់ពិតជាបានប្រទានពរដល់ពួកគាត់បានកូនប្រុស១មែន។ ប៉ុន្តែកូនតូចនេះបានទៅនៅស្ថានសួគ៌ ពេលអាយុទើបតែបាន១ឆ្នាំជាង។ ពួកគាត់ពិតជាលំបាកចិត្តខ្លាំងណាស់ តែព្រះ បានបន្តប្រទានព្រះគុណនិងការកំសាន្តចិត្តដល់ពួកគាត់។ គន្ធាត្រូវបានគេនិយាយថាបានចូលរួមចំណែកយ៉ាងសកម្មបំផុតក្នុងជីវិតរបស់ប្រជាជន និងគាំទ្រយ៉ាងខ្លាំងដល់ស្វាមីរបស់គាត់ក្នុងការបម្រើព័ន្ធកិច្ច។ សេចក្ដីស្រឡាញ់គ្នាទៅវិញទៅមក ហើយនិងការប្ដេជ្ញាចិត្តរបស់ពួកគាត់ចំពោះព្រះជាម្ចាស់និងតាមព្រះហឫទ័យទ្រង់ បានបង្ហាញឲ្យឃើញតាមរយៈការតស៊ូសម្រាប់ដំណឹងល្អ និងការបង្កើតផលផ្លែយ៉ាងច្រើនរបស់ពួកគាត់។

សូមអធិស្ឋានសម្រាប់ពួកគាត់ សុំព្រះជាម្ចាស់ការពារព្រះវិហាររបស់ទ្រង់ពីពួកគ្រូខុសឆ្គង។ សូមអធិស្ឋានសម្រាប់អ្នកដឹកនាំពួកជំនុំផងដែរ ដែលពួកគាត់កំពុងផ្សព្វផ្សាយពីសេចក្ដីជំនឿដល់ក្រុមកុលសម្ព័ន្ធផ្សេងៗ។ សូមឲ្យពួកគេបន្តលូតលាស់ក្នុងសេចក្ដីជំនឿតាមរយៈការអធិស្ឋាននិងការសិក្សាព្រះគម្ពីរ។

## ប្រតិទិនសិក្សាសម្រាប់ឆមាសទី២ :

***ឆមាសទី២ ២៣កុម្ភៈ-២៦មិថុនា ២០១៥***

២៤-២៥ កុម្ភៈ ការវាយតម្លៃការសិក្សារបស់និស្សិត
១៣ មីនា ទិវាខួបកំណើតសាលាលើកទី២៣
១៩-២០ មីនា ទិវាកីឡានៃសាលាព្រះគម្ពីរភ្នំពេញ
២៩មិថុនា-២កក្កដា ការប្រឡងដំណាច់ឆមាសទី២
៧ កក្កដា ការវាយតម្លៃការសិក្សានាដំណាច់ឆ្នាំ សម្រាប់ឆ្នាំទី៤/បរិញ្ញាបត្ររង
៨-១១ កក្កដា សកម្មភាពតាមថ្នាក់
១៣-១៤ កក្កដា ការវាយតម្លៃការសិក្សានាដំណាច់ឆ្នាំ(ឆ្នាំទី១-៣)
១៧ កក្កដា ពិធីអរព្រះគុណនាដំណាច់ឆ្នាំសិក្សា
២៤ កក្កដា ពិធីប្រគល់សញ្ញាបត្រលើកទី២១

## សេចក្ដីអធិស្ឋាន :

សូមអធិស្ឋានសម្រាប់PPBSពេលលោកគ្រូទេព សំណាងឈប់ពីទីនេះ ទៅដឹកនាំនៅEFC សូមឲ្យថ្នាក់ ដឹកនាំសាលានឹងអាចបំពេញតួនាទីបានល្អ។ សូមអធិស្ឋានសម្រាប់លោកគ្រូទេពសំណាង និងគ្រួសារអាចចុះសម្រុងនឹងព័ន្ធកិច្ចថ្មី។

សូមព្រះប្រទានប្រាជ្ញាសម្រាប់គណកម្មការនាយកដឹកនាំសាលានិងនិមិត្តសម្រាប់អនាគតនៃPPBS។

អធិស្ឋានសម្រាប់លោកគ្រូ ស៊ុន វុទ្ធីនិងគ្រួសារ ក្នុងពេលដែលគាត់ទទួលតួនាទីជាមហាវិទ្យាធិការស្ដីទីរបស់PPBS និងបន្តធ្វើជានាយកកម្មវិធីសិក្សាផងដែរ។ អធិស្ឋានសម្រាប់លោកគ្រូតាំងណារី ដែលគាត់បន្តបំពេញតួនាទីជាមហាវិទ្យាធិការរង និងជាប្រធានរដ្ឋបាល។

អធិស្ឋានសម្រាប់ក្រុមសាស្ត្រាចារ្យ និងបុគ្គលិកដើរជិតស្និទ្ធិជាមួយព្រះជាម្ចាស់ និងជាមួយគ្នាទៅវិញទៅមកដើម្បីឲ្យពួកគាត់អាចបង្រៀននិងដឹកនាំនិស្សិតបានល្អប្រសើរ។

អធិស្ឋានឲ្យនិស្សិតមានសុខភាពល្អ និងកម្លាំងដើម្បីសិក្សាបានល្អ ជិតស្និទ្ធជាមួយព្រះ និងធ្វើព័ន្ធកិច្ចរបស់ពួកគេដើម្បីលើកដំកើងសិរីល្អព្រះ។

---

***យើងខ្ញុំសូមថ្លែងអំណរគុណចំពោះជង្វាយរបស់លោកអ្នក!***

នាម:______________________ អស័យដ្ឋាន ឬ អ៊ីមែល:______________________
លេខទូរស័ព្ទ:______________________ មកពីពួកជំនុំឬអង្គការ: ______________________

**របៀបដែលលោកអ្នកអាចថ្វាយជង្វាយ:**

$__________________ ឬ ថ្វាយជង្វាយរបស់លោកអ្នកដោយបញ្ចូលទៅក្នុងធនាគារកម្ពុជាសាធារណៈ គណនីលេខ # ០៩០ ០២ ១១ ០០ ១៥២១ ឬប្រគល់ជូនផ្ទាល់ដល់ផ្នែកហិរញ្ញវត្ថុរបស់សាលាព្រះគម្ពីរភ្នំពេញ។

**សូមបញ្ជាក់ឲ្យបានច្បាស់ជង្វាយរបស់លោកអ្នកសម្រាប់:**

- ការប្រើប្រាស់ទូទៅ ☐
- ឧបត្ថម្ភដល់និស្សិត ☐
- អភិវឌ្ឍអាគារសិក្សា ☐
- ឧបត្ថម្ភដល់បណ្ណាល័យ ☐
- ឧបត្ថម្ភដល់ការបំពាក់គ្រឿងបរិក្ខាសាលា ☐

#២៥៥ ផ្លូវ២៨គ្រួសារ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រ ១១៥៤ ទូរស័ព្ទលេខ ០១២ ៩៣៩ ៥០៤
អ៊ីមែល ppbs@ppbs.edu.kh វិបសាយ www.ppbs.edu.kh